ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំ

# ស្តីពី

# នីតិវិធីនៃការទូទាត់សាច់ប្រាក់

# នៅក្នុងទីផ្សារមូលបត្រ

ចែករំលែកដោយ៖

សមាគមឈ្មួញជើងសារឧបករណ៍និស្សន្ទនៅកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:...០០៣/១២...គ.ម.ក /សៈជ.លា.

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១២

**គោលការណ៍ណែនាំ**

**ស្តីពី**

**នីតិវិធីនៃការទូទាត់សាច់ប្រាក់នៅក្នុងទីផ្សារមូលបត្រ**

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវគោលនយោបាយពាក់ព័ន្ធនឹងការកំណត់រូបិយវត្ថុ ឬរូបិយបណ្ណ សម្រាប់ចារឹកលើមូលបត្របោះផ្សាយលក់ជាសាធារណៈ និងសម្រាប់ការជួញដូរនៅក្នុងទីផ្សារមូលបត្រកម្ពុជា ដូចខាងក្រោម÷

១-មូលបត្រដែលបោះផ្សាយលក់ជាសាធារណៈ ត្រូវចារឹកជាប្រាក់រៀល។

២-ការដាក់តម្លៃលើមូលបត្រ (Quotation) នៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (Cambodia Securities Exchange-CSX) ត្រូវធ្វើជាប្រាក់រៀល។

៣-ការទូទាត់នៅក្នុងទីផ្សារដំបូង (Primary Market) និងនៅក្នុងទីផ្សារបន្ទាប់ (Secondary Market) ត្រូវធ្វើជាប្រាក់រៀល។ ប៉ុន្តែបើភាគីអ្នកទិញ និងអ្នកលក់មូលបត្រមានការឯកភាពគ្នាក្នុងការទូទាត់ជាប្រាក់ដុល្លារអាមេរិក នោះការទូទាត់អាចធ្វើឡើងជាប្រាក់ដុល្លារអាមេរិក។ ការទូទាត់ជាប្រាក់ដុល្លារអាមេរិកនេះ ត្រូវបានអនុញ្ញាតឱ្យធ្វើក្នុងរយៈពេល ០៣ (បី) ឆ្នាំដំបូង ចាប់ពីទីផ្សារមូលបត្រត្រូវបានបង្កើត។

ដើម្បីសម្រួលដល់ការអនុវត្តគោលនយោបាយខាងលើនេះ គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) សូមចេញនូវគោលការណ៍ណែនាំដូចខាងក្រោម÷

## I-ការទូទាត់សាច់ប្រាក់នៅក្នុងទីផ្សារដំបូង

### ១-ក្រុមហ៊ុនធានាទិញមូលបត្រ

ដើម្បីឱ្យវិនិយោគិនដែលធ្វើបរិវិសកម្មក្នុងទីផ្សារដំបូងអាចទូទាត់ជាប្រាក់រៀល ឬប្រាក់ដុល្លារអាមេរិកបាន ក្រុមហ៊ុនធានាទិញមូលបត្រត្រូវមានគណនី ០២ (ពីរ) ជាគណនីប្រាក់រៀលផង និងប្រាក់ដុល្លារអាមេរិកផងនៅក្នុងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីទទួលបង្កាក់សាច់ប្រាក់របស់អ្នកធ្វើបរិវិសកម្ម ។

### ២-អ្នកធ្វើបរិវិសកម្ម

ក្នុងករណីដែលអ្នកធ្វើបរិវិសកម្មមានបំណងទូទាត់ជាប្រាក់រៀល ត្រូវដាក់បង្កាក់សាច់ប្រាក់ជាប្រាក់រៀលចំនួនយ៉ាងតិច ១០០% នៃទំហំបរិវិសកម្មដែលត្រូវធ្វើ។ ក្នុងករណីដែលអ្នកធ្វើបរិវិសកម្មមានបំណងទូទាត់ជាប្រាក់ដុល្លារអាមេរិក ត្រូវដាក់បង្កាក់សាច់ប្រាក់ជាប្រាក់ដុល្លារអាមេរិកចំនួនយ៉ាងតិច ១១០% នៃទំហំបរិវិសកម្មដែលត្រូវធ្វើ ដោយយកតាមអត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា នៅ ០១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទចាប់ផ្តើមទទួលពាក្យស្នើសុំធ្វើបរិវិសកម្ម។

### ៣-ការទូទាត់

ក្រោយពេលធ្វើបរិវិសកម្មបានសម្រេច អ្នកធ្វើបរិវិសកម្មដែលមានបំណងធ្វើការទូទាត់ជាប្រាក់ដុល្លារអាមេរិក ត្រូវរកការព្រមព្រៀងជាមួយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រលើអត្រាប្តូរប្រាក់ ដោយអត្រានេះត្រូវស្ថិតក្នុងរង្វង់

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

±១% នៃអត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា នៅកាលបរិច្ឆេទនៃការព្រមព្រៀងគ្នា ឬយ៉ាងយូរត្រឹម ០២ (ពីរ) ថ្ងៃនៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទទូទាត់។ ក្នុងករណីដែលអ្នកធ្វើបរិវិសកម្មដាក់បង្កកសាច់ប្រាក់ជាប្រាក់ដុល្លារអាមេរិក មិនអាចរកបានកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ដើម្បីទូទាត់ជាប្រាក់ដុល្លារអាមេរិក នោះអ្នកធ្វើបរិវិសកម្មអាចរកប្រាក់រៀលដើម្បីទូទាត់ មុននឹងអាចដកសាច់ប្រាក់ជាប្រាក់ដុល្លារអាមេរិក ដែលបានបង្កក ឬប្តូរសាច់ប្រាក់ដុល្លារដែលបានបង្កក ទៅជាប្រាក់រៀលដើម្បីទូទាត់។

**II-ការទូទាត់សាច់ប្រាក់នៅក្នុងទីផ្សារបន្ទាប់**

**១-ក្រុមហ៊ុនមូលបត្រ**

ដើម្បីផ្តល់ជម្រើសដល់វិនិយោគិនក្នុងការទូទាត់សាច់ប្រាក់ជាប្រាក់រៀល ឬជាប្រាក់ដុល្លារអាមេរិក ក្រុមហ៊ុនមូលបត្រ ត្រូវបើកគណនីសាច់ប្រាក់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រជាគណនីប្រាក់រៀលផង និងគណនីប្រាក់ដុល្លារអាមេរិកផង។

**២-ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវបើកគណនីទូទាត់សាច់ប្រាក់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រជាគណនីប្រាក់រៀល ដើម្បីធ្វើការទូទាត់សាច់ប្រាក់ជាប្រាក់រៀល តាមប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**៣-អ្នកបញ្ជាលក់/ទិញមូលបត្រ**

ការបញ្ជាលក់/ទិញ ការជួញដូរ និងការទូទាត់តាមរយៈក្រុមហ៊ុនមូលបត្រ ទៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវធ្វើឡើងជាប្រាក់រៀល។ អ្នកបញ្ជាទិញមូលបត្រត្រូវដាក់បង្កកសាច់ប្រាក់ជាប្រាក់រៀលចំនួនយ៉ាងតិច ១០០% នៃទំហំបញ្ជាទិញ។ ប៉ុន្តែអ្នកលក់និងអ្នកទិញ ដោយមានការជ្រោមជ្រែងពីក្រុមហ៊ុនមូលបត្រ ឬ/និងភ្នាក់ងារទូទាត់សាច់-ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ អាចរកកិច្ចព្រមព្រៀងទូទាត់សាច់ប្រាក់ជាប្រាក់ដុល្លារអាមេរិក បន្ទាប់ពីការទូទាត់ជាប្រាក់រៀល តាមរយៈប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**៤-ការទូទាត់**

ក្រុមហ៊ុនមូលបត្រត្រូវចាត់ចែងរៀបចំបង្វែរសាច់ប្រាក់ដែលត្រូវទូទាត់ តាមរយៈភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ យ៉ាងយូរត្រឹមម៉ោង ៨:៣០ នាទីព្រឹក នៃកាលបរិច្ឆេទទូទាត់ (T+2) ទៅគណនីទូទាត់សាច់-ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ។ បន្ទាប់ពីម៉ោង ៨:៣០ នាទីព្រឹក នៅថ្ងៃដដែល នៅកាល-បរិច្ឆេទទូទាត់ (T+2) ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវបង្វែរសាច់ប្រាក់បន្តទៅឱ្យសមាជិកដែលត្រូវទទួលការទូទាត់ យ៉ាងយូរត្រឹមម៉ោង ១០:៣០ នាទីព្រឹក នៃកាលបរិច្ឆេទទូទាត់ (T+2)។ បន្ទាប់ពីម៉ោង ១០:៣០ នាទីព្រឹក ក្រុមហ៊ុនមូលបត្រត្រូវផ្ទេរសាច់ប្រាក់ទៅគណនីអតិថិជនរបស់ខ្លួនឱ្យចប់សព្វគ្រប់ ក្នុងកាលបរិច្ឆេទទូទាត់ (T+2) នេះ។

ដោយការជួញដូរ និងការទូទាត់ត្រូវធ្វើឡើងជាប្រាក់រៀល តាមរយៈប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា អតិថិជនដែលមានបំណងធ្វើការទូទាត់ជាប្រាក់ដុល្លារអាមេរិក ត្រូវបញ្ជាក់ទៅក្រុមហ៊ុនមូលបត្រ ឬ/និងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីរកកិច្ចព្រមព្រៀងលើអត្រាប្តូរប្រាក់ជាមួយសមភាគីសម្រាប់ធ្វើការទូទាត់ជាប្រាក់ដុល្លារអាមេរិក។

**គណៈកម្មការមូលបត្រកម្ពុជា**